THE SCHOOL DISTRICT OF PHILADELPHIA

**Office of Communications**
Suite 301
440 North Broad Street
Philadelphia, PA 19130

ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០២២

ជូនចំពោះ ក្រុមគ្រួសារ និងសិស្សានុសិស្សរបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា៖

ថ្ងៃចូលរៀនដំបូង នៅសល់តែ១០ថ្ងៃទៀតទេ! យើងពិតជារំភើបរីករាយក្នុងការស្វាគមន៍សិស្សានុសិស្ស ក្រុមគ្រួសារ និងបុគ្គលិករបស់យើងមកកាន់ឆ្នាំសិក្សា ២០២២-២៣ ដែលចាប់ផ្តើមនៅថ្ងៃ ច័ន្ទ ទី ២៩ ខែ សីហា។ ប្រសិនបើលោកអ្នកមិនទាន់បានឃើញការផ្សាយរបស់យើងនៅលើកញ្ចក់ទូរទស្សន៍នៅឡើយ លោកអ្នកអាចមើលនៅ ត្រង់នេះ។

នេះគឺជាការរំលឹកមួយចំនួនដើម្បីជួយលោកអ្នករៀបចំសម្រាប់ការចាប់ផ្តើមឆ្នាំសិក្សាឱ្យមានជោគជ័យ៖

- **ពិធីការសុខភាព និងសុវត្ថិភាព** - ដូចដែលបានចែករំលែកកាលពីសប្តាហ៍មុន **សិស្ស និងបុគ្គលិកទាំងអស់នឹងត្រូវតម្រូវឱ្យពាក់ម៉ាស់ពេលនៅក្នុងសាលារយៈពេល ១០ ថ្ងៃដំបូង នៃឆ្នាំសិក្សាថ្មី** - **ចាប់ពីថ្ងៃទី ២៩ ខែ សីហា ដល់ ថ្ងៃទី ៩ ខែ កញ្ញា ដោយមិនគិតពីកម្រិត ខូវីដ-១៩ នៅក្នុងសហគមន៍។** នេះគឺជាការប្រុងប្រយ័ត្នបន្ថែមសម្រាប់សុខភាព និងសុខុមាលភាពរបស់អ្នករាល់គ្នា ដោយសារការកើនឡើងនៃការជួបជុំគ្នានៅចុងរដូវក្តៅអាចបង្កើនហានិភ័យនៃការឆ្លងរោគ ខូវីដ-១៩ ។ បន្ទាប់មក ការពាក់ម៉ាស់អាចក្លាយជាជម្រើស យោងទៅតាមកាលៈទេសៈ។ លោកអ្នកអាចចូលទៅកាន់ មជ្ឈមណ្ឌលផ្ទុកព័ត៌មាន ខូវីដ-១៩ របស់យើង ដើម្បីចុះឈ្មោះសម្រាប់អង្គប្រជុំស្តីពីសុខភាព និងសុវត្ថិភាព នាពេលខាងមុខ ចូលមើល ការណែនាំខ្លីៗនូវអ្វីដែលត្រូវធ្វើសម្រាប់ក្រុមគ្រួសារ និងអានពិធីការទូទៅសម្រាប់ ខូវីដ-១៩ សម្រាប់ឆ្នាំសិក្សា ២០២២-២០២៣។
- **សំណួរ? ទាក់ទងបុគ្គលិកសាលាដែលអាចជួយបាន** - បញ្ជីដែលងាយស្រួលប្រើ នេះ ផ្តល់នូវព័ត៌មានសម្រាប់ទាក់ទង និងជំនួយដើម្បីជួយលោកអ្នកក្នុងការទទួលជំនួយដែលលោកអ្នកត្រូវការ ជាមួយនឹងការអប់រំ ថ្នាក់រៀន និងសាលារបស់កូនលោកអ្នក។ លោកអ្នកក៏អាចប្រើបណ្តាញទូរស័ព្ទបន្ទាន់ដែលមានច្រើនភាសារបស់យើងនៅ ត្រង់នេះ ផងដែរ។

- **បញ្ជីផ្ទៀងផ្ទាត់សម្រាប់ការចូលរៀនវិញ** - មកទល់ពេលនេះ លោកអ្នកគួរតែទទួល [បញ្ជីផ្ទៀងផ្ទាត់] នេះ នៅក្នុងប្រអប់សំបុត្ររបស់លោកអ្នក ជាមួយនឹងគន្លឹះដើម្បីជួយលោកអ្នករៀបចំ។ ធ្វើយ៉ាងណាត្រូវមើលវាឱ្យបានមុនពេលសាលាចាប់ផ្តើម។

- **ប្រតិទិន ឆ្នាំ ២០២២-២០២៣** - លោកអ្នកអាចមើលប្រតិទិនតាមអ៊ិនធ័រណិតនៅ [ត្រង់នេះ]។ ធ្វើយ៉ាងណាត្រូវកត់សម្គាល់ថ្ងៃដែលសាលានឹងឱ្យសិស្សចេញមុនបីម៉ោង ឬបិទសម្រាប់សិស្ស ដើម្បីទុកពេលបន្ថែមឱ្យអ្នកអប់រំរបស់យើងសម្រាប់ការហ្វឹកហ្វឺនវិជ្ជាជីវៈ និងការរៀបចំផែនការបង្ហាត់បង្រៀន។

- **ពិធីការសម្រាប់ថ្ងៃក្តៅខ្លាំង** - រដូវក្តៅនេះ ទីក្រុងហ្វីឡាដែលហ្វ្យា បានជួបប្រទះសីតុណ្ហភាពដែលក្តៅលើសពីធម្មតា។ ប្រសិនបើមានកំដៅក្តៅខ្លាំងកើតឡើងបន្ទាប់ពីសាលាចាប់ផ្តើម យើងចង់ឱ្យលោកអ្នកដឹងពីអ្វីដែលត្រូវរំពឹងទុក នៅពេលដែលយើងចាត់ចែងដើម្បីការពារសុខភាព និងសុខុមាលភាពរបស់អ្នករាល់គ្នាដែលនៅក្នុងអគារសិក្សារបស់យើង។
    - អ្នកទទួលខុសត្រូវអគាររបស់យើងឃ្លាំមើលយ៉ាងសកម្មនូវសីតុណ្ហភាពនៅក្នុងអគារសិក្សានីមួយៗ នៅពេលណាដែលសីតុណ្ហភាពខាងក្រៅត្រូវបានព្យាករណ៍ថានឹងឡើងដល់ 85°F ឬក្តៅជាងនេះ ឬនៅពេលដែលសន្ទស្សន៍កំដៅឡើងដល់ 90°F ឬក្តៅជាងនេះ ត្រូវបានប្រមាណទុកជាមុន។
    - យើងមានការប្រុងប្រយ័ត្នបន្ថែមនៅក្នុងអគារសិក្សា (សូមមើលបញ្ជីខាងក្រោម) ដែលបច្ចុប្បន្ននេះមានម៉ាស៊ីនត្រជាក់តាមបង្អួច ជំនួសប្រព័ន្ធម៉ាស៊ីនត្រជាក់ធំដែលអាចគ្រប់គ្រងសីតុណ្ហភាពមិនឱ្យផ្លាស់ប្តូរនៅក្នុងកន្លែងបង្រៀន។
    - ប្រសិនបើយើងរំពឹងទុកថាសីតុណ្ហភាពនៅក្នុងអគារសិក្សានឹងឡើងដល់ 90°F ឬក្តៅជាងនេះ យើងនឹងសហការជាមួយថ្នាក់ដឹកនាំសាលាដើម្បីសម្រេចថាតើការផ្លាស់ប្តូរបណ្តោះអាសន្នទៅរៀនតាមអ៊ិនធ័រណិតជាការចាំបាច់សម្រាប់សុវត្ថិភាពរបស់អ្នកទាំងអស់ដែរឬអត់។ គោលបំណងរបស់យើងគឺធ្វើការសម្រេចចិត្តឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន យកល្អមួយថ្ងៃមុន ដើម្បីកាត់បន្ថយការរំខានដល់សិស្ស ក្រុមគ្រួសារ និងបុគ្គលិករបស់យើង។
    - ធ្វើយ៉ាងណាត្រូវមើល [ការរក្សាសុវត្ថិភាពក្មេងនៅពេលសីតុណ្ហភាពក្តៅខ្លាំង] នេះ សម្រាប់គន្លឹះដែលមានប្រយោជន៍ផ្សេងៗទៀត។

ក្រុមប្រតិបត្តិការរបស់យើងបន្តធ្វើការយ៉ាងខិតខំប្រឹងប្រែង ក្នុងការធ្វើឱ្យអគារសិក្សាទូទាំងក្រសួងកាន់តែប្រសើរឡើង ដែលនឹងផ្តល់បរិយាកាសសិក្សាដែលប្រកបដោយសុវត្ថិភាព និងជាសុកភាពនៅគ្រប់

សាលា។ យើងទន្ទឹងរង់ចាំការចែករំលែក ផែនការរៀបចំអគារសិក្សា (Facilities Master Plan) ដែលនឹងបង្ហាញជូនក្រុមប្រឹក្សាអប់រំនៅនិទាឃរដូវ នៃឆ្នាំ ២០២៣ ហើយនឹងបង្ហាញពីផែនការរួមរបស់យើង ដើម្បីគាំទ្រដល់បរិយាកាសបង្ហាត់បង្រៀន និងរៀនសូត្រដ៏អស្ចារ្យ សម្រាប់សិស្ស និងបុគ្គលិកទាំងអស់របស់យើង។ រហូតដល់ពេលនោះ យើងនឹងបន្តដំណើរការរបស់យើងដើម្បីកែលម្អប្រព័ន្ធម៉ាស៊ីនត្រជាក់នៅក្នុងសាលា។

សូមអរគុណចំពោះការជ្រើសរើសក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វៀ សម្រាប់តម្រូវការអប់រំរបស់កូនលោកអ្នក។ យើងទន្ទឹងរង់ចាំជួបលោកអ្នកនៅថ្ងៃទី ២៩ ខែ សីហា។

*ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វៀ*
*ការិយាល័យទំនាក់ទំនង*

*សាលាដែលត្រូវការ ការកែលម្អប្រព័ន្ធម៉ាស៊ីនត្រជាក់ និង/ឬ ប្រព័ន្ធអគ្គិសនី

| | | |
|---|---|---|
| AMY @ James Martin MS | Franklin Learning Center HS | Morris, Robert ES |
| AMY Northwest MS | Furness, Horace HS | Morrison, Andrew J. ES |
| Arthur, Chester A. ES | Gideon, Edward ES | Nebinger, George W. ES |
| Bache-Martin ES | Girard Academic Music Program HS | Olney ES |
| Barton, Clara ES | Girard, Stephen ES | Overbrook Educational Center Annex ES |
| Blaine, James G. ES | Girls HS | Overbrook ES |
| Blankenburg, Rudolph ES | Greenberg, Joseph ES | Parkway West HS |
| Bregy, Amedee F. ES | Hamilton, Andrew ES | Patterson, John M. ES |
| Brown, Henry A. ES | Harding, Warren G. MS | Penn Treaty HS |
| Bryant, William C. ES | Harrington, Avery D. ES | Pennell, Joseph ES |
| Building 21 HS | Henry, Charles W. ES | Pennypacker, Samuel ES |
| Casarez, Gloria ES | Hill-Freedman World Academy MS | Penrose ES |
| Castor Gardens MS | Holme, Thomas ES | Rhawnhurst ES |
| Catharine, Joseph W. ES | Hopkinson, Francis ES | Roosevelt, Theodore ES |

| | | |
|---|---|---|
| Central HS | Houston, Henry H. ES | Rowen, William ES |
| Childs, George W. ES | Howe, Julia W. ES | Roxborough HS |
| Comegys, Benjamin B. ES | Jenks, Abram ES | Sayre, William HS |
| Comly, Watson ES | Jenks Academy for Arts & Sciences ES | Sharswood, George ES |
| Conwell Annex MS | Kenderton ES | Shawmont ES |
| Cooke, Jay ES | Key, Francis Scott ES | Sheppard, Issac A. ES |
| Coppin, Fanny Jackson ES | Kirkbride, Eliza B. ES | Science Leadership Academy @ Beeber HS |
| Crossan, Kennedy C. ES | Lamberton, Robert E. ES | South Philadelphia HS |
| Day, Anna B. ES | Lea, Henry C. ES | Spring Garden ES |
| Disston, Hamilton ES | Lingelbach, Anna L . ES | Spruance, Gilbert ES |
| Dobson, James ES | Loesche, William H. ES | Sullivan, James J. ES |
| Dunbar, Paul L. ES | Logan, James ES | Taggart, John H. ES |
| Edmonds, Franklin S. ES | Lowell, James R. ES | Tilden, William MS |
| Ellwood ES | Ludlow, James R. ES | The U School HS |
| Emlen, Eleanor C. ES | Marshall, John ES | Wagner, Gen. Louis MS |
| Fell, D. Newlin ES | McCloskey, John F. ES | Waring, Laura W. ES |
| Finletter, Thomas K. ES | McClure, Alexander K. ES | Washington, George HS |
| Fitler Academic Plus ES | McMichael, Morton ES | Washington, Martha ES |
| Fitzpatrick, A.L. ES | Meredith, William M. ES | Welsh, John ES |
| Fox Chase ES | Mifflin, Thomas ES | Ziegler, William H. ES |
| Franklin, Benjamin ES | Mitchell ES | |
| Franklin, Benjamin HS | Moore, J. Hampton ES | |